# ប្រាសាទភ្នំឈ្យោក

ប្រាសាទភ្នំឈ្យោក មានទីតាំងស្ថិតនៅភូមិមានរិទ្ធ ឃុំត្រពាំងព្រីង ស្រុកកំពត ខេត្តកំពត ដែលមានចម្ងាយប្រមាណ១២គីឡូម៉ែត្រ ភាគខាងកើតទីរួមខេត្តកំពត។ ប្រាសាទនេះធ្លាប់បាន សិក្សាស្រាវជ្រាវដោយអ្នកសិក្សាខ្មែរ និងបរទេសជាច្រើនរូបមកហើយ ជាពិសេស គឺការសិក្សា ដំបូងៗដោយអ្នកស្រាវជ្រាវជនជាតិបារាំង មានដូចជា លោក Etienne Aymonier លោក Lunet De Lajonquière លោក Henri Parmentier និងលោក Goerge Coedès ជាដើម។ តើប្រាសាទនេះមាន លក្ខណៈបែបណាខ្លះ និងទំនងសាងសង់ឡើងនៅស.វ.ទីប៉ុន្មាន?

ប្រាសាទភ្នំឈ្យោក សាងសង់ឡើងអំពីឥដ្ឋនៅក្នុងរូងភ្នំថ្មកំបោរមួយ ជាបន្ទប់មានរាងបួន ជ្រុងស្មើ និងផ្នែកខាងមុខមានយ៉លយចេញទៅទិសខាងលិច ហើយផ្នែកដំបូលធ្វើឡើងជាបីថ្នាក់ តាមទម្រង់ប្រាសាទបែបដ្រាវិទ (Drãvida) នៃសិល្បៈឥណ្ឌាខាងត្បូង (រូបលេខ១-២)។ លក្ខណៈ ពិសេសមួយដែលគេអាចកត់សម្គាល់នោះគឺ ប្រាសាទនេះសង់គ្របពីលើលិង្គធម្មជាតិមួយដែល ជាប្រភេទថ្មកំបោរ និងមានសង់ស្នានទ្រនិមួយអំពីថ្មភក់សម្រាប់ជាទម្រសិវលិង្គ (រូបលេខ៣)។ សព្វថ្ងៃ នៅលើទ្វារចូលប្រាសាទយើងឃើញនៅសល់បំណែកផ្តែរទ្វារធ្វើអំពីឥដ្ឋ (រូបលេខ៤) ដែលចុងសងខាងមានចម្លាក់រូបសត្វមករបែរមុខចូលក្នុងខ្ជាក់ក្បាច់អង្កត់ធ្នូដែលមានរាងកោងក្នុង ទម្រង់ស្រដៀងផ្តែរជាច្រើនដែលយើងឃើញនៅតំបន់ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង (ឧទាហរណ៍ ប្រាសាទបាដើម) (រូបលេខ៥) និងស្រដៀងផ្តែរទ្វារនៅគុកព្រះធាតុ (ភ្នំហាន់ជ័យ) ខេត្តកំពង់ចាម (រូបលេខ៦)។ ក្រៅពីនេះ នៅខាងលើផ្តែរទ្វារយើងឃើញមានហោជាងរាងដូចដើងក លម្អដោយ ក្បាច់ផ្សេងៗ ដែលយើងអាចចាត់បញ្ចូលបានថា ទំនងជាហោជាងប្រាសាទធ្វើអំពីឥដ្ឋដ៏ចំណាស់ មួយក្នុងសិល្បៈខ្មែរដែលនៅមានរូបរាងល្អ (រូបលេខ៧)។

នៅប្រាសាទភ្នំឈ្យោក គេធ្លាប់រកឃើញសិលាចារឹកមួយចារឹកអក្សរពីរជ្រុង ដែលជ្រុងទីមួយ មានចំនួន ១១បន្ទាត់ និងជ្រុងទីពីរមានចំនួន ១៣បន្ទាត់ ចុះបញ្ជីលេខ K.46 ចារឹកជាភាសា សំស្ក្រឹតនិងភាសាខ្មែរបុរាណ ប៉ុន្តែផ្នែកខាងភាសាសំស្ក្រឹតបានរលុបស្ទើរអស់ នាំឱ្យគេមិនអាចប្រែ សេចក្តីបានឡើយ។ សិលាចារឹកនេះមិនបានផ្តល់កាលបរិច្ឆេទណាមួយឱ្យគេដឹងឡើយ ហើយ អត្ថន័យជាទូទៅនៅក្នុងសេចក្តីជាភាសាខ្មែរបានរៀបរាប់អំពីតង្វាយរបស់ម្ចាស់ទាន ម្រតាញសិរ និងបោញផ្ទានកុមារ ថ្វាយដល់ព្រះអាទិទេពព្រះនាម "ព្រះកម្រតាងអញស្រីឧត្បន្នេស្វរ" (ព្រះ នាមមួយរបស់ព្រះឥសូរ ដែលពាក្យ **ឧត្បន្ន** មានន័យថា "**ដែលកើតឡើងហើយ**") មានជង្វាយដូច ជា គោ ក្របី ស្រែ ស្វា ដូង កឱល និងក្ញុំបម្រើព្រះស្រីប្រុសជាច្រើននាក់ ហើយមានដាក់បណ្តាសា

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ឱ្យធ្លាក់នរកចំពោះជនណាដែលបានលួចទ្រព្យទាំងនេះទៀតផង។[១] លោក Aymonier និងលោក Coedès យល់ស្របគ្នាថា សិលាចារឹកនេះទំនងចារឡើងនៅរវាងស.វ.ទី៧ នៃគ.ស.។[២]

ក្នុងការកំណត់អាយុកាលរបស់ប្រាសាទនេះ គឺពិតជាមានភាពលំបាកបន្តិច ដោយសារអត្ថបទផ្នែកខាងលើរបស់សិលាចារឹកទាំងពីរជ្រុងជាភាសាសំស្ក្រឹតសុទ្ធតែរលុប ដែលធ្វើឱ្យយើងបាត់កស្តុតាងសំខាន់។ ឥឡូវ យើងសាកល្បងយកព្រះនាមរបស់ទេពដែលគេថ្វាយដង្វាយនៅក្នុងសិលាចារឹកមកសិក្សា គឺទេពមានព្រះនាមថា "ព្រះកម្រតាងអញស្រីឧត្បន្នេស្វរ"។ ព្រះនាមនេះ គេធ្លាប់ឃើញមាននៅក្នុងសិលាចារឹកគុហាហ្លួង ខេត្តកំពត (K.44) សិលាចារឹកវត្តគិរីទេសពិជ ខេត្តកំពង់ស្ពឺ សិលាចារឹកគង់ពិសី ខេត្តកំពង់ស្ពឺ (K.1298)។ ក្នុងនោះ សិលាចារឹកវត្តគិរីទេសពិជ និងសិលាចារឹកគង់ពិសី ក៏មិនបានផ្តល់កាលបរិច្ឆេទដែរ ប៉ុន្តែបើមើលតាមអក្សរលោក កំ វណ្ណារ៉ា បានសន្និដ្ឋានថាជាចារឹកស.វ.ទី៧ ដូចសិលាចារឹកប្រាសាទភ្នំឈ្លោកដែរ។[៣] ចំណែក សិលាចារឹកគុហាហ្លួង ខេត្តកំពត (K.44) មានចារឹកកាលបរិច្ឆេទនៃឆ្នាំចារឹកអក្សរ គឺមហាសករាជឆ្នាំ ៥៩៦ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៦៧៤ ដែលត្រូវនឹងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី១ (គ.ស.៦៥៧-៦៨១)។[៤] សេចក្តីជាទូទៅនៃសិលាចារឹកគុហាហ្លួង បានរៀបរាប់អំពីព្រះរាជបញ្ជារបស់ព្រះបាទជ័យវរ្ម័នទី១ សម្រាប់ការធ្វើតង្វាយថ្វាយដល់អាទិទេព "**ព្រះកម្រតាងអញស្រីឧត្បន្នេស្វរ**" ។ ប៉ុន្តែ អ្វីដែលយើងគួរកត់សម្គាល់នោះគឺ នៅបន្ទាត់ទី១០ នៃជ្រុងទី១ មានរៀបរាប់ឱ្យដឹងថា អំណោយដែលគេថ្វាយដល់ប្រាសាទនេះមានតាំងពីជំនាន់ព្រះបាទរុទ្រវរ្ម័ន (គ.ស.៥១៥-៥៥០) ដែលគេច្រើនយល់ថាទ្រង់ជាព្រះមហាក្សត្រចុងក្រោយរបស់អាណាចក្រហ្វូណន។[៥] ហេតុដូច្នេះ ប្រសិនបើមើលតាមទិន្នន័យសិលាចារឹកនេះ ហាក់ដូចជាចង់បញ្ជាក់ថា ទីសក្ការបូជាដែលនៅគុហាហ្លួងនោះ អាចមានអាយុកាលតាំងពីជំនាន់ព្រះបាទរុទ្រវរ្ម័នមកក៏អាចថាបាន ឬគេអាចសាងបន្ថែមទៀតនៅសម័យក្រោយក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១។ ទោះបីជាយ៉ាងណា តាមទិន្នន័យសិលាចារឹកភ្នំឈ្លោកឯណោះវិញ យើងនៅតែពិបាកកំណត់ថា ប្រាសាទភ្នំឈ្លោកសង់ឡើងនៅស.វ.ទីប៉ុន្មាន និងរជ្ជកាលស្តេចអង្គណាឱ្យបានប្រាកដណាស់។ ប្រសិនយើងផ្តល់ការសន្និដ្ឋានអាយុកាលប្រាសាទភ្នំឈ្លោកប្រហាក់ប្រហែលគុហាហ្លួង ប្រាសាទភ្នំឈ្លោកទំនងសាងសង់ឡើងនៅរវាងពាក់កណ្តាលស.វ.ទី៦ រវាងរជ្ជកាល

---

[១] Aymonier 1900: 154; Coedès 1954: 34.

[២] Ibid.

[៣] កំ វណ្ណារ៉ា ២០១៩: ១៨២-១៨៦; ២១០-២១១។

[៤] Coedès 1950: 10.

[៥] Ibid.

ព្រះបាទរុទ្រវរ្ម័ន។ ប៉ុន្តែបើយើងឱ្យអាយុកាលប្រហាក់ប្រហែលប្រាសាទគុកព្រះធាតុនៅភ្នំហាន់ជ័យ អាចមានអាយុកាលនៅចុងស.វ.ទី៦ ឬដើមស.វ.ទី៧ រវាងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ហើយបើសិនជាឱ្យអាយុកាលប្រហាក់ប្រហែលក្រុមប្រាសាទនៅតំបន់ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ប្រាសាទភ្នំឈ្ងោកអាចទំនងសាងឡើងនៅចុងស.វ.ទី៦ ដើមស.វ.ទី៧ រវាងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ឬព្រះបាទមហេន្ទ្រវរ្ម័ន។

ជារួមមក ប្រាសាទភ្នំឈ្ងោក គឺជាប្រាសាទមួយឧទ្ទិសដល់ព្រហ្មញ្ញសាសនា (ព្រះឥសូរ) ដែលគេចាត់ទុកថាជាសំណង់ក្នុងរូងភ្នំដែលចាស់ជាងគេនៅក្នុងសិល្បៈខ្មែរ (នៅមានរូបរាងល្អ)។ ចំពោះ អាយុកាលរបស់ប្រាសាទនេះ យើងពុំអាចផ្តល់អាយុកាលជាក់លាក់ណាមួយបានឡើយ តែយើងអាចសន្និដ្ឋានបានថា ប្រាសាទភ្នំឈ្ងោកទំនងសង់ឡើងនៅរវាងចន្លោះពាក់កណ្តាលស.វ. ទី៦ ដល់ដើមស.វ.ទី៧នៃគ.ស. ពោល គឺចាប់ពីរវាងចន្លោះរជ្ជកាលព្រះបាទរុទ្រវរ្ម័ន (គ.ស.៥១៥-៥៥០) ដល់រជ្ជកាលព្រះបាទមហេន្ទ្រវរ្ម័ន (៦០៦-៦១៦)។ ទោះជាយ៉ាងណាក្តី យើងជឿថាប្រាសាទនេះទំនងជាមានអាយុកាលមុនក្រុមប្រាសាទនៅតំបន់សំបូរព្រៃគុក ខេត្តកំពង់ធំ ដែលភាគច្រើនជាសំណង់ក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧)៕

## ឯកសារយោង

**កំ វណ្ណារ៉ា**

២០១៩, ប្រជុំសិលាចារឹកខេត្តកំពង់ស្ពឺ, ភ្នំពេញ

**Coedès, Goerge**

1950, *Inscription du Cambodge,* Tome 2, Hanoi

1954, *Inscription du Cambodge,* Tome 6, Hanoi

**Lajonquière, Lunet**

1902, "*Inventaire descriptive des monuments du Cambodge*", Paris

**Parmentier, Henri**

1927, "*L'art Khmer primitif*", Paris

អត្ថបទដោយៈ ម៉ង់ វ៉ាលី



រូបលេខ១៖ ប្រាសាទភ្នំឈ្លោក មើលចំពីមុខខាងលិច (រូបថត៖ លោក ស៊ីផាន់ណា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រាសាទភ្នំឈ្លោក មើលចំពីមុខនិរតី (រូបថត៖ លាក់ ស៊ីផាន់ណា)



រូបលេខ៣៖ លិង្គធម្មជាតិនៅខាងក្នុងប្រាសាទ (រូបថត៖ លាក់ ស៊ីផាន់ណា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ បំណែកផ្តែរទ្វារប្រាសាទភ្នំឈ្សោក (រូបថត៖ លាក់ ស៊ីផាន់ណា)



រូបលេខ២៥៖ ផ្តែរទ្វារប្រាសាទបាដើម ខេត្តស្ទឹងត្រែង (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៦៖ ផ្តែរទ្វារប្រាសាទគុកព្រះធាតុ ភ្នំហាន់ជ័យ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៧៖ ផ្តែរទ្វារនិងហោជាងប្រាសាទភ្នំឈ្មោក មើលចំពីមុខ (រូបថត៖ លាក់ ស៊ីផាន់ណា)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី